# ប្រភពនៃការអប់រំក្នុងពិភពលោកចាប់ពីមជ្ឈិមសម័យ

*ដោយ៖* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម រាជបណ្ឌិត្យសភាកម្ពុជា*

## ១-វប្បធម៌ និងការអប់រំនៅមជ្ឈិមសម័យ

### ក-ឱនភាព បន្ទាប់មកការនិយមឡើងវិញក្នុងការសិក្សា

*ប្រវត្តិវិទូ បានកំណត់យកសហសវត្ស នៅចន្លោះឱនភាពនៃក្រុងរ៉ូម និងបុនសម័យ (៥០០-១៤០០គ.ស.) ថាជាមជ្ឈិមសម័យ* (Middle Ages or midieval period)*។ សករាជនៃវប្បធម៌ និងការអប់រំលោកខាងលិចនេះ បានលាតសន្ធឹងពីចុងបញ្ចប់នៃសករាជក្លាស៊ីករ៉ូម៉ាំង-ក្រិក និងការចាប់ផ្តើមនៃអ្វីដែលយើងហៅថានវសម័យ។ វាត្រូវបានកំណត់ជាលើកដំបូងដោយឱនភាពក្នុងការសិក្សា ហើយបន្ទាប់មក ដោយការនិយមឡើងវិញនៃពួកអ្នកអប់រំដែលមានវិជ្ជាជ្រៅជ្រះ។*

### ខ-ស្ថាប័ននៃការសិក្សា

*ក្រោយពេលដែលចក្រភពរ៉ូម៉ាំងខាងលិច ត្រូវបានដួលរលំទៅ ព្រះវិហារកាតូលិក* (The Chatolic Church) *ដែលត្រូវបានដឹកនាំដោយសម្តេចប៉ូប* (The pope) *ក្នុងទីក្រុងរ៉ូមនោះ ពោរពេញទៅដោយភាពគ្មានអ្នកគ្រប់គ្រងផ្នែកអប់រំ វប្បធម៌ នយោបាយ ដែលទទួលបានលទ្ធផលឡើយ។ ក្នុងអំឡុងពេលមជ្ឈិមសម័យ ការអប់រំក្នុងប្រព័ន្ធនៅបឋមសិក្សាអឺរ៉ុប បានធ្លាក់ទៅលើព្រះវិហារក្នុងសាលារៀនបព្វជិត អ្នកស្រុកដើងវត្ត។ នៅកម្រិតមធ្យមសិក្សាទាំងសាលាបព្វជិត ទាំងមហាព្រះវិហារ ផ្តល់កម្មវិធីសិក្សាទូទៅ។ ឧត្តមសិក្សា បានកើតឡើងឡើងនៅក្នុងសាកលវិទ្យាល័យនៃក្រុង* Paris, Bologna, Salerno, Oxford, and Cambridge[1]*។ ពាណិជ្ជករ និងអ្នកមានវិជ្ជាជីវៈរកស៊ីក្នុងសង្គម ក៏បានបង្កើតសាលារៀនមួយចំនួន ដែលផ្តល់ការអប់រំមូលដ្ឋាន ព្រមទាំងបណ្តុះបណ្តាលពាណិជ្ជកម្ម។ អស្សប្ញទ្ធិ សិក្សាយុទ្ធសាស្ត្រទ័ព និងគោលការណ៍ ភាពជាអ្នកក្លាហានប្រកបដោយសីលធម៌ក្នុងប្រាសាទនានា។*

---

[1] C. Stephen Jaeger, *The Envy of Engels: Cathedral Schools and Social Ideals in Medieval Europe, 950-1200* (Philaidelphia: University of Pennsylvania Press, 1994), p.153.

**គ-ការចូលសិក្សា**

នៅក្នុងសករាជគ្រិក និងរ៉ូម៉ាំងមុននេះ មនុស្សតិចតួចបំផុត បានចូលសិក្សានៅមជ្ឈិមសម័យ ជាបឋមមនុស្សប្រុសដែលមានផែនការចូលទៅក្នុងវិជ្ជាជីវៈ សាសនា ក្នុងនាមជាបព្វជិត ព្រះសង្ឃ ឬសមាជិកនៃបទបញ្ញាបព្វជិត។ មនុស្សមួយភាគធំបំផុត គឺជាសេវកា ដែលជាកម្មករកសិកម្ម នៅលើទ្រព្យសម្បត្តិម្ចាស់ដីពួកសក្តិភូមិនោះ ជាទូទៅជាអនក្ខរជន។

**ឃ-ការអប់រំស្ត្រី នៅមជ្ឈិមសម័យ**

លក្ខខណ្ឌស្ត្រី ក្នុងសង្គមមជ្ឈិមសម័យ មានភាពផ្សេងៗគ្នា ទៅតាមវណ្ណៈ សេដ្ឋកិច្ច សង្គមរបស់គេ។ ទោះបីជាសាសនាគ្រិស្ត នៅមជ្ឈិមសម័យ បានសង្កត់ធ្ងន់ទៅលើសមភាព ខាងស្មារតីនៃស្ត្រី និងធម្មជាតិនៃអាពាហ៍ពិពាហ៍ទៅតាមសច្ចាប្រណិធានក្តី ស្ត្រីនៅតែបន្តមានតួនាទី ដែលបានបញ្ញត្តខាងផ្លូវសមធម៌ គេទតាមប្រពៃណី។ ទាសី និងវណ្ណៈកសិករ បានសិក្សាពីផ្ទះសម្បែង និងកិច្ចការចិញ្ចឹមកូនជាធម្មតា តាមការគ្រាប់តាមមាតារបស់ពួកគេ។ ស្ត្រីវណ្ណៈអភិជន ក៏បានធ្វើតាមផងដែរនូវបញ្ញត្តិនៃវណ្ណៈរបស់ខ្លួនគេ និងបានសិក្សាពីតួនាទី ដ៏សមរម្យទៅ នឹងគោលការណ៍នៃភាពក្លាហានដែលប្រកបដោយសីលធម៌(Chivalry) ដែលជាញឹកញាប់មានបំណងចាត់ចែងជីវិតនៅក្នុងគេហដ្ឋានដ៏ស្កុកស្កម្ភ និងនៅក្នុងប្រាសាទ។ ព្រះវិហារនៅមជ្ឈិមសម័យ បានផ្តល់នូវឱកាសអប់រំ សម្រាប់ស្ត្រីតាមរយៈសហគមន៍សាសនា។ អារាំសដូនជីដូចជាវត្តទាំងឡាយ មានបណ្ណាល័យនិងសាលារៀន ដើម្បីត្រៀមរៀបចំដូនជី ធ្វើតាមវិធានសាសនានៃសហគមន៍របស់ពួកគេ។

**៧ - ១ - Aquinas: ការអប់រំប្រកបដោយភាពមានវិជ្ជាជ្រៅជ្រះ**

**ក-ជំនឿ និងហេតុផល រួមបញ្ចូលគ្នា**

នៅត្រឹមសតវត្សទី១១ អ្នកអប់រំនាមជ្ឈិមសម័យ បានអភិវឌ្ឍប្រព័ន្ធទស្សនវិជ្ជា ដែលផ្អែកលើសិទ្ធាន្តសាសនវិទ្យា (Scholasticism) ដែលជាវិធីមួយនៃការអង្កេតភាពមានវិជ្ជាជ្រៅជ្រះ និងការបង្រៀន។ បព្វជិត ដែលជាអ្នកបង្រៀនផ្អែកលើជំនឿ និងហេតុផល ជាប្រភពនៃជំនឿបន្ថែម។ ពួកគេបានទទួលយកគម្ពីរពិសិដ្ឋ និងការនិពន្ធរបស់បិតាព្រះវិហារថា ជាប្រភពនៃពាក្យ ដែលបានលាតត្រដាងដោយព្រះ។ គ្រូបង្រៀន ដែលជា

---

[2] Judith M. Bennet, *Medieval Women in Modern Perspective* (Washington, D.C.: Americal Historical Associa- tion, 2000).

បព្វជិត ជឿជាក់ថា ចិត្តរបស់មនុស្សអាចធ្វើគោលការណ៍អនុមានលើកទីមួយដែល (នៅពេលដែលបំភ្លឺឱ្យច្បាស់ ដោយប្រភពព្រះគម្ពីរ) ជាប្រភពនៃជំនឿ។

**ខ-ការផ្សះផ្សារព្រះគម្ពីរ ជាមួយវិចារក្រិក**

ទស្សនវិជ្ជា ដែលមានវិជ្ជាជ្រៅជ្រះ និងការអប់រំ បានឈានដល់ភាពកំពូល (Zenith) នៅក្នុង *The Summa Theologiae* of Saint Thomas Aquinas(1225-1274) ជាសាសនវិទូ Domi-nican នៅសាកលវិទ្យាល័យប៉ារីស។ Aquinas ត្រូវបានយកចិត្តទុកដាក់ជាលើកដំបូងជាមួយការផ្សះផ្សារប្រភពទាំងឡាយ ដែលជាការផ្សារភ្ជាប់ជំនឿតាមព្រះគម្ពីរ ជាមួយទស្សនវិជ្ជាក្រិករបស់អារីស្តូត។ Aquinas បានប្រើប្រាស់ទាំងជំនឿទាំងវិចារ ដើម្បីឆ្លើយសំណួរជាមូលដ្ឋានអំពីបញ្ញត្តិ ព្រះរបស់សាសនាគ្រិស្ត ដែលជាធម្មជាតិមនុស្ស និងចក្រវាឡ ហើយនិងទំនាក់ទំនងរវាងព្រះ និងមនុស្ស[3]។ សម្រាប់ Aquinas មនុស្ស បានដំណើរការរចនាទៅដោយផ្នែករាងកាយ និងផ្នែកព្រលឹង។ ទោះបីជាគេរស់នៅជាបណ្ដោះអាសន្នលើផែនដី គោលបំណងកំពូលរបស់គេដើម្បីទទួលយកបទពិសោធអនន្តភាពជាមួយព្រះ។ ដូចអារីស្តូត Aquinas អះអាងថា ចំណេះដឹងរបស់មនុស្ស ចាប់ផ្ដើមតាមឥន្ទ្រីយារម្មណ៍ ហើយបញ្ចប់ដោយបញ្ញត្តិនីយកម្ម។

នៅក្នុងស្នាដៃ de Magistro (Concerning teacher) Aquinas បានបរិយាយវិជ្ជាជីវៈរបស់គ្រូថា ជាជំនឿផ្សំគ្នា គឺក្ដីស្រឡាញ់ និងការសិក្សា។ គ្រូបង្រៀនជាវិជ្ជាករដែលចេះសញ្ជឹងគិត ភ្នាក់ងារសិក្សាសកម្ម ជំនាញការលើមុខវិជ្ជា អ្នកបង្រៀនប្រកបដោយបំណិន និងជាអ្នក ស្រឡាញ់មនុស្ស។

**គ-មុខវិជ្ជាដែលជាកម្មវត្ថុសិក្សា**

គ្រូបង្រៀន ដែលមានវិជ្ជាជ្រៅជ្រះជាបព្វជិត ហើយសាលារៀនត្រូវបានគ្រប់គ្រង និងការពារដោយព្រះវិហារ។ កម្មវិធីសិក្សា ត្រូវបានរៀបចំឱ្យទៅជាមុខវិជ្ជាផ្លូវការ ដោយអនុវត្ត តាមប្រពៃណីសិល្បៈសេរី ដូចជានៅឧត្តមសិក្សា មុខវិជ្ជា ត្រូវមាន តក្កវិទ្យា គណិតវិទ្យា ទស្សនវិជ្ជាសីលធម៌ និងធម្មជាតិ បរមត្ថវិទ្យា និងសាសនវិទ្យា។ ក្នុងការបង្រៀនរបស់ខ្លួន គ្រូត្រូវប្រើអំណះអំណាងប្រកបដោយតក្កវិទ្យា គឺវិចារអនុមានញែក (Deductive reasoning) ដើម្បីបង្កើតអង្គពុទ្ធិដែលត្រូវ

[3] *Francis J. Selman, Saint Thomas Aquinas: Teacher of Truth (Edinburg, Scotland: T& Clark, 1994); and Etienne Gilson, The Christian Philosophy of Saint Aquinas (Notre Dame, Ind.: University of Notre Dame Press, 1994.*

បានរៀបចំរួចហើយ។ វាសង្កត់ធ្ងន់ទៅលើគោលការណ៍មូលដ្ឋាន និងការអនុវត្ត។ ក្នុងការបន្ថែមទៅលើការសិក្សាក្នុងប្រព័ន្ធ Aquinas បានទទួលស្គាល់សារៈសំខាន់នៃការអប់រំមិនផ្លូវការ តាមរយៈគ្រួសារ មិត្តភ័ក្ត្រ និងបរិស្ថាន[4]។

នៅក្រោយកាលដ៏យូរនៃមជ្ឈិមសម័យ និងរហូតមកដល់ពេលបច្ចុប្បន្ន ទស្សនវិជ្ជារបស់Aquinas ត្រូវបានគេហៅថា Thomism បានជះឥទ្ធិពលដល់ការអប់រំក្នុងវិហារកាតូលិក ដែលវាត្រូវបានប្រើជាមូលដ្ឋាននៃសាលារៀន ដែលមានជំនឿទៅលើសាលារៀន។ នៅក្នុងសហរដ្ឋអាម៉េរិក សាលារៀនកាតូលិក គឺជាប្រព័ន្ធសាលារៀនមិនមែនសាធារណៈដ៏ធំបំផុត ដែលមានសិស្ស ចុះឈ្មោះចូលរៀនចំនួន ២,៥១១,០៤០នាក់ នៅក្នុងសាលារៀនចំនួន៨,១០២សាលា[5]។ Thomism ក៏បានជះឥទ្ធិពលផងដែរ ដល់ពួកមនុស្សនិយមដែលមិនមែនជាសាសនា ដូចជា Mortimer Adler ដែលបានអភិវឌ្ឍសំណើ Paideia (បកស្រាយនៅពេលក្រោយ)។

**៧-២-ការរួមចំណែកពីមជ្ឈិមសម័យ ចំពោះការអប់រំលោកខាងលិច**

**ចំណេះដឹងដែលបានរក្សាទុក និងការបង្កើតគ្រឹះស្ថានអប់រំ**

អ្នកអប់រំមជ្ឈិមសម័យ បានរួមចំណែកដល់ការអប់រំមជ្ឈិមសម័យជាបឋម គឺតាមការរក្សាទុក និងការបង្កើតគ្រឹះស្ថានអប់រំ គឺថា តាមការបង្ហាញវាជាមួយក្របខណ្ឌ ដែលបានរៀបចំត្រឹមត្រូវ។ សាលារៀនព្រះវិហារ វត្ត និងជើងវត្តទាំងអស់ បានផ្ទេរចំណេះដឹងតាមរបៀបនេះ។ តួយ៉ាងនៃនិន្នាការនេះ គឺជាសាកលវិទ្យាល័យមជ្ឈិមសម័យ ដែលជាមូលដ្ឋានគ្រឹះសម្រាប់សាកលវិទ្យាល័យទំនើប។ ជាមួយកំពែងទាំងនេះ អ្នកអប់រំមជ្ឈិមសម័យ មិនគ្រាន់តែបានបង្រៀនទេ ប៉ុន្តែ ថែមទាំងបានរក្សាទុកចំណេះដឹង តាមការកត់ត្រា និងប្រមូលចងក្រងជាក្រុមទៀតផងដែរ។

## ៨-មនុស្សនិយមនៅបុនសម័យ

### ក-ការនិយមឡើងវិញនូវទិដ្ឋភាពនៃក្លាស៊ិក

បុនសម័យ ដែលបានចាប់ផ្ដើមក្នុងសតវត្សទី១៤ ហើយឈានដល់ចំណុចកំពូលក្នុងសតវត្សទី១៥ ដោយកត់សម្គាល់ ទៅលើការនិយមឡើងវិញនូវទិដ្ឋភាពមនុស្សនិយមនៃអក្សរសាស្ត្រឡាតាំង និងក្រិក។ វាត្រូវបានគេចាត់ទុកជារយៈពេលអន្តរកាល រវាងមជ្ឈិមសម័យ និងនវសម័យ។ អ្នកប្រាជ្ញបុនសម័យនៃមនុស្សនិយមក្លាស៊ិក ដូចជាការ

---

[4] John W. Donohue. *St. Thomas Aquinas and Education* (New York: Random House, 1968), pp. 76-79.

[5] Private School Universe Survey, 1999-2000, http: nces.ed.gov/pubsearch (01/12/2003).

អប់រំ និងសាលារៀនមជ្ឈិមសម័យ បានបង្កើតប្រកពជំនាញរបស់គេក្នុងអតីតកាល និងសង្កត់ធ្ងន់លើអក្សរសិល្ប៍ក្លាស៊ិក។ ទោះជាយ៉ាងនេះក្ដី មិនដូចទស្សនវិជ្ជាមជ្ឈិមសម័យទេ ពួកមនុស្សនិយមក្លាស៊ិកយកចិត្តទុកដាក់តែទៅលើអក្សរសិល្ប៍ជាងសាសនវិទ្យា[6]។

**ខ-មនុស្សនិយមបែបក្លាស៊ិកក្នុងប្រទេសអ៊ីតាលី**

បុនសម័យត្រូវបានគេកត់សម្គាល់ជាពិសេសក្នុងប្រទេសអ៊ីតាលី ជាកន្លែងដែលការរស់ឡើងវិញខាងពាណិជ្ជកម្មផ្ដល់មូលនិធិដ៏ច្រើនពីសិល្បៈ និងអក្សរសាស្ត្រ។ មនុស្សនិយមក្លាស៊ិកអ៊ីតាលីដោយចាត់ទុកខ្លួនឯងជាវរជនអក្សរសាស្ត្រនោះ គឺត្រូវបានស្វ័យប្រកាសថា ឆ្មាំចំណេះដឹង (Custodians of knowledge)។ នៅអ៊ីតាលី ស្នាដៃDante, Petrarch, and Boccaccio បានជំរុះបញ្ចាំងការនិយមឡើងវិញ ផ្នែកអក្សរសាស្ត្រមនុស្សនិយម។ ពួកអភិជនអ៊ីតាលី បានបង្កើតសាលារៀនមនុស្សនិយម ដើម្បីរៀបចំកុមារក្នុងការសិក្សាបែបក្លាស៊ិក ដែលត្រូវនិយមឡើងវិញ។

**គ-ពួកបរិវារស្ដេចជាគំរូមួយ**

ដោយជំទាស់ទៅនឹងប្រព័ន្ធទស្សនវិជ្ជាសិទ្ធាន្តសាសនា អ្នកអប់រំមនុស្សនិយមក្លាស៊ិក បានត្រឡប់សាជាថ្មីទៅរកអ៊ីសូក្រាត (Isocrates and Quintilian)។ ក្នុងអក្សរសិល្ប៍ក្រិក និងឡាតាំង គេបានរកឃើញគំរូនៃឧត្ដមភាពអក្សរសាស្ត្រ និងរចនាបថ ឧត្ដមគតិនៃមនុស្ស ដែលមានការអប់រំ និងទស្សនៈគតិបណ្ឌិតបុរាណកាល ដែលគួរស្រឡាញ់ជាទីបំផុត។ សម្រាប់អ្នកអប់រំមនុស្សនិយម ពួកបរិវារស្ដេច បានក្លាយជាមនុស្សគំរូ ដែលមានការអប់រំ។ មនុស្សម្នាក់ ដែលបែបបទ និងភាពថ្លៃថ្នូរ ត្រូវអប់រំដោយសេរីក្នុងអក្សរសាស្ត្រក្លាស៊ិក។ ពួកបរិវារស្ដេច ជាអ្នកការទូតដ៏ប៉ិនប្រសប់ ដែលអាចធ្វើជាអ្នកគ្រប់គ្រងដ៏ល្អក្នុងកិច្ចការរបស់រដ្ឋ។ Baldesar Casti- gliore (1478-1529) បានពិពណ៌នាពួកបរិវារស្ដេច និងការអប់រំ ដែលមានសារៈសំខាន់ដល់ អក្សរសាស្ត្រក្រិក និងឡាតាំង ព្រមទាំងសេចក្ដីគួរសមតាមរបៀបបរិវារស្ដេចក្នុងសៀវភៅរបស់គាត់ The Book of the Courtier[7]។

---

[6] J. R. Hale, *Renaissance Europe* (New York: Basli Blackwell, 2000).

[7] Baldesar Castigliore, *The Book of the Courtier*, trans. C. S. Singleton (New York: Doubleday, 1959). A Commentary is Peter Burke, *The Fortunes of Courtiers: The European Reception of Castigliore's Cortigiano* (University Park: Pennsylvania State University Press, 1996).

### ឃ-ការគិតដ៏ល្អិតល្អន់

អ្នកអប់រំមនុស្សនិយមបុនសម័យ ជាមនុស្ស ដែលមានការចេះដឹងខាងអក្សរសាស្ត្រ ដូចជា អ្នកនិពន្ធ កវី អ្នកបកប្រែ និង អ្នករិះគន់។ គ្រូបង្រៀនដែលជាសិល្បករ អ្នករិះគន់សង្គម និងការនិយម ពួកគេនាំមកនូវការប៉ិនប្រសប់កំប្លែង សម្រស់ និង ការនិពន្ធដៀលត្មះ ព្រមទាំង**ពហុសុតភាព**ចំពោះការងាររបស់ពួកគេ។ ដោយប្រមើលមើលការបញ្ជាក់អះអាង នាពេលសព្វថ្ងៃនេះ ទៅលើការគិតល្អិតល្អន់នោះ ពួកគេស្វែងរកអប់រំមនុស្ស ដែលមានចិត្តគិតបានល្អិតល្អន់ ដែលអាចប្រឆាំងនឹង ទំនៀមទម្លាប់ ដែលមានរួចហើយបង្ហាញ និងកែភាពសមរម្យ ក្នុងអក្សរសាស្ត្រ និង ជីវិត។ នៅក្នុងអឺរ៉ុបប៉ែកខាងជើង ពួកអ្នកប្រាជ្ញមនុស្សនិយម បានពិនិត្យយ៉ាងល្អិតល្អន់នូវស្នាដៃសាសនវិទ្យាមជ្ឈិមសម័យ។

ប៉ុន្តែ ពួកមនុស្សនិយមបុនសម័យ ជាញឹកញាប់ បានចៀសវាងវាងខ្លួនឯង និងចំនួនមនុស្សដ៏ច្រើន ដោយដកយកបញ្ញត្តិដ៏សំខាន់នៃធម្មជាតិមនុស្ស ពីអក្សរសាស្ត្រ ដែលមានវ័យចំណាស់ដោយប្រុងប្រយ័ត្ន។ នៅពេលដែលស្រាទំពាំងបាយជូរ ដែលបានផលិតដ៏ល្អ ត្រូវបានគេប្រើប្រាស់ដើម្បីលំអអាហារល្ងាចដ៏ថ្លៃថ្នូរនោះ ការអប់រំមនុស្សនិយម គឺជាមនុស្ស ដែលស្គាល់ពីស្ថានភាពពិតប្រាកដ។ វាមិនត្រូវបានគេផ្តល់ឱ្យជនគ្រប់គ្នានោះទេ តែរក្សាទុកសម្រាប់វរជន។

### ខ-ការចូលរៀនដែលមានកំណត់

បុនសម័យ មិនបានពង្រីកការយកចិត្តទុកដាក់ ដល់សាលារៀនខ្លាំងពេកទេ។ ពួកមនុស្សនិយម ដែលបានត្រៀមរៀបចំទុក(បឋមសិក្សា) និងសាលាមធ្យមសិក្សា បានអប់រំកុមារ អភិជន និងវណ្ណៈខ្ពស់។ សាលាបឋមសិក្សា បានបម្រើវណ្ណៈពាណិជ្ជកម្មកណ្តាល។ កុមារដែលមានវណ្ណៈសេដ្ឋកិច្ចសង្គមទាប បានទទួលការអប់រំក្នុងប្រព័ន្ធតិចតួច។

### ៨-១-Erasmus: អ្នករិះគន់ និងមនុស្សនិយមពិទូ

#### ក- Erasmus អំពីការអប់រំ

Desiderius Erasmus (28 October 1466-12 July 1536, Dutch) ជាមនុស្សនិយមវិទូក្លាស៊ីក ដែលនាំមុខគេ នៅបុនសម័យ ដែលត្រូវបានពណ៌នា ថាជាគ្រូគំរូក្នុងនាមជាមនុស្សនិយមសកល[8]។ ឥរិយាបថរបស់គ្រូមនុស្សនិយមវិទូសកល គួរតែផ្តល់នូវបឋមវិធានក្នុងសិល្បៈសេរី ជាពិសេសនៅក្នុងមុខវិជ្ជា ដូចជាអក្សរសាស្ត្រ ភាសា ប្រវត្តិវិទ្យា និងសាសនា ដែលមាន

[8] For Biographies of Erasmus, see Leon E. Halkin, *Erasmus: A Critical Biography* (Oxford, U.K., and Cambri- dge, Mass.: Basil Blackwell, 1993); and James McConics, *Erasmus* (New York: Oxford University Press, 1991).

ប្រយោជន៍ នៅក្នុងការបកប្រែស្នាដៃក្លាស៊ិក។ ដូចជាQuintilianដែរ Erasmus មានទស្សនៈ ទូលំទូលាយពីការអប់រំ ការផ្តល់ដំបូន្មាន ដល់មាតាបិតា ដែលការអប់រំ នៅសម័យ ដើម មានភាពចាំបាច់ក្នុងការបង្កើត តរិយាបថ និងអាកប្បកិរិយាកុមារ សម្រាប់ ការអប់រំសម័យក្រោយ។ កុមារ ត្រូវបានគេ ផ្តល់សិទ្ធិឱ្យមាតាបិតា និងគ្រូ ដែលជាគំរូ នៃសេចក្តីគួរសម (Civility) និងវប្បធម៌។

**ខ-ការលើកកម្ពស់ដល់សៀវភៅ និងអក្សរសិល្ប៍**

ក្នុងនាមជាមនុស្សនិយម Erasmus មានការព្រួយបារម្ភបំផុត ជាមួយការ បង្រៀនអក្សរសិល្ប៍។ គាត់បានផ្តល់ យោបល់ថា ការជំរុញសិស្សឱ្យអាន សៀវភៅល្អៗ តាមការឱ្យពួកគេ ស្រាវជ្រាវ អត្ថន័យរបស់អ្នកនិពន្ធ នៅក្នុងជីវិតផ្ទាល់ ខ្លួនរបស់ពួកគេ។ គាត់បានលើកទឹកចិត្ត គ្រូ បង្រៀនឱ្យប្រើប្រាស់ការសន្ទនា ល្បែង និងសកម្មភាពទាំងឡាយ ដើម្បីពន្យល់ អត្ថន័យនៃសៀវភៅ។ Erasmus បាន អភិវឌ្ឍវិធីដូចតទៅ ដើម្បីបង្រៀនអក្សរ សិល្ប៍៖

1-បង្ហាញជីវប្រវត្តិរបស់អ្នកនិពន្ធ។

2-កំណត់អត្តសញ្ញាណប្រភេទនៃសៀវភៅ។

3-ពិភាក្សាដំណើរសាច់រឿង។

4-ឆ្លុះបញ្ចាំងទៅលើការអនុវត្ត ផ្នែកទស្សនវិជ្ជា និងសីលធម៌របស់សៀវភៅ។

5-វិភាគរចនាបថនិពន្ធរបស់អ្នកនិពន្ធ[9]។

**គ-ការប្រឆាំងជំទាស់ ចំពោះ អំពើហិង្សា**

ការជំទាស់របស់Erasmus ចំពោះ សង្គ្រាម និងហិង្សា ត្រូវបានគេបង្ហាញឱ្យ ឃើញក្នុងសៀវភៅរបស់គាត់មានឈ្មោះ ថា ការអប់រំព្រះអង្គម្ចាស់ ដែលជា គ្រិស្តសាសនិក(១៥១៦) (The Education of the Christian Prince)[10]។ គាត់បានផ្តល់ ដំបូន្មានដល់អ្នកទាំងឡាយ ដែលនឹងធ្វើ ជា គ្រូបង្រៀនទោលដល់ព្រះអង្គម្ចាស់ ដើម្បីឱ្យជឿជាក់ថា ព្រះអង្គ បានសិក្សា បានច្រើនដូច ដែលគាត់អាច អំពីប្រជាជន នៃព្រះរាជាណាចក្ររបស់ព្រះអង្គ ដូចជា ប្រពៃណី ទំនៀមទម្លាប់ ស្នាដៃ និងបញ្ហា ទាំងឡាយ។ មិនដូច្នោះ Machiavelli ដែល បានអះអាងថា ព្រះរាជាគួរតែគ្រប់គ្រង ដោយសេចក្តីកោតក្រែង និងភាពប៉ិន ប្រសប់ ឬសម្របសម្រួលនោះ Erasmus បានផ្តល់ ដំបូន្មានដល់ព្រះអង្គម្ចាស់ ឱ្យ ទទួលបានសេចក្តីស្រឡាញ់ពីមុខវិជ្ជា របស់ខ្លួន ហើយនិងសិក្សា សិល្បៈនៃសន្តិ

[9] William H. Woodward, *Desiderius Erasmus: Concerning the Aim and Method of Education* (New York: Teachers College Press, 1994).

[10] Robert D. Sider and John B.Payne, eds. *Collected Works of Erasmus* (Toronto: University of Toronto Press, 1990).

ភាព ជាពិសេសការទូត និងជៀសវាង សង្គ្រាម។

**៨-២-មុនសម័យដល់ការអប់រំលោកខាងលិច**

**ក-ការបញ្ជាក់ន័យទៅលើអក្សរសិល្ប៍ និងភាសាក្លាស៊ីក**

ពួកមនុស្សនិយមវិទូបុនសម័យ បានសង្កត់ធ្ងន់ទៅលើចំណេះដឹងភាសាក្រិក និងឡាតាំង ថាជាសញ្ញាសម្គាល់ពិតនៃមនុស្ស ដែលមានការអប់រំ។ អស់រយៈពេលជាច្រើនសតវត្ស ចំណូលចិត្តមនុស្សនិយមវិទូក្លាស៊ីក បានបង្កើតការអប់រំមធ្យមសិក្សា និងឧត្តមសិក្សាលោកខាងលិច។ នៅទ្វីបអឺរ៉ុប និងសហរដ្ឋអាម៉េរិក សាលាវិជ្ជាជីវៈ មហាវិទ្យាល័យ និងសាកលវិទ្យាល័យជាច្រើន តម្រូវឱ្យមានចំណេះដឹងខាងភាសាឡាតាំង សម្រាប់ការចូលរៀន រហូតដល់ចុងសតវត្សទី១៩។

**ខ-ចំណេះដឹងខាងមនុស្សនិយម (មិនមែនខាងវិទ្យាសាស្ត្រ)**

វាជារឿងសំខាន់ផងដែរ ដើម្បីកត់សម្គាល់ថា Erasmus និងអ្នកអប់រំបុនសម័យផ្សេងទៀត កំពុងជំរុញដល់បញ្ញត្តិនៃចំណេះដឹងខាងមនុស្សនិយម ឬមជ្ឈមណ្ឌលមនុស្ស។ ជាជាងការឈានទៅដល់ប្រធានបទមនុស្សនិយមរបស់គេតាមរយៈការអង្កេតបែបវិទ្យាសាស្ត្រ នោះអ្នកអប់រំមនុស្សនិយម បានស្រាវជ្រាវការយកចិត្តទុកដាក់របស់គេ តាមអក្សរសិល្ប៍។ ក្រោយមកគោលវិធីនេះអាចទប់ទល់បាននឹងកំណែទម្រង់របស់ Rousseau, Comenius, Pesta- lozzi, and Dewey ដែលអ្នកទាំងអស់គ្នា បានពោលអាងប្រឆាំង នឹងការបង្រៀន ដែលបានសង្កត់ធ្ងន់ទៅលើអក្សរសិល្ប៍ នៅពេលដែលមិនបានយកចិត្តទុកដាក់ទៅលើបទពិសោធ។

**គ-រោងពុម្ព**

ការច្នៃប្រឌិតរោងពុម្ពក្នុងឆ្នាំ ១៤២៣ ក្នុងទ្វីបអឺរ៉ុប បានធ្វើឱ្យជឿនលឿនដល់អក្ខរកម្ម និងការសិក្សាអប់រំគួរឱ្យចាប់ចិត្ត។ មុនពេលមានរោងពុម្ព សិស្សបានចម្លងដោយផ្ទិតផ្ទង់នូវការសរសេរតាមអានពីគ្រូ។ ការបង្រៀននៅសាកលវិទ្យាល័យ គឺជាបទពិសោធពិសេសចាំបាច់ ដែលក្នុងនោះសិស្ស ឬនិស្សិត កត់ត្រាពាក្យសម្ដីរបស់សាស្ត្រាចារ្យរបស់ពួកគេ។

ត្រឹមពាក់កណ្ដាលសតវត្សទី១៥ ពួកអឺរ៉ុបបានធ្វងកាត់នូវបទពិសោធជាមួយនឹងប្រភេទលោហធាតុ ដែលអាចធ្វើចលនាបាន។ Johannes Gutenberg ជាងទងជាតិអាល្លឺម៉ង់ម្នាក់ បានប្រឌិតសំលោហធាតុដ៏រឹងមាំ ដើម្បីបង្កើតអក្សរសម្រាប់រោងពុម្ព។ គម្ពីររបស់គាត់ក្នុងឆ្នាំ ១៤៥៥ គឺជាសៀវភៅលើកដំបូង ដែលបានបោះពុម្ពបែបនោះ។ ការបោះពុម្ព

បានរាលដាលពាសពេញទ្វីបអឺរ៉ុប ដោយផលិតផលកើនឡើងច្រើនជាងមុន ហើយនិងកាត់បន្ថយចំណាយ ទៅលើសៀវភៅ។ វាបង្កើតព័ត៌មានដែលអាចឈានទៅដល់ការអាន ដែលមានភាពទូលំទូលាយជាងមុន[11]។ វាជានវកម្មបច្ចេកទេសដ៏សំខាន់ ដែលផលរបស់វា នាំមកដល់ការសាយភាយព័ត៌មានកុំព្យូទ័រ។

## ៩-ការកែទម្រង់ខាងសាសនា និងការអប់រំ

### ក-សេរីភាពពីប្រភពអំណាចសម្តេចសង្ឃប៉ុប (ប៉ាប ជាភាសាបារាំង)

ការកែទម្រង់ខាងសាសនា នៅសតវត្សទី១៦និងទី១៧ ត្រូវបានធ្វើឱ្យមានការរំដើបរំជួល ដោយការរិះគន់ពួកមនុស្សនិយម នៅអឺរ៉ុបខាងជើងនៃស្ថាប័ន និងអំណាចនៅមជ្ឈិមសម័យ។ នៅពេលដែលពួកមនុស្សនិយម បានជំនួសប្រព័ន្ធទស្សនវិជ្ជាសិទ្ធាន្តសាសនវិទ្យានោះ អំណាចកណ្តាលរបស់ព្រះវិហារកាតូលិក ដើម្បីដាក់ឱ្យប្រតិបត្តិភាពដូចគ្នាខាងសាសនា បានកាត់បន្ថយបន្តិចម្តងៗ។ រឿងនេះ បានត្រួសត្រាយផ្លូវឱ្យមតិខាងសាសនាផ្សេងៗគ្នា ដែលនាំឱ្យមានជម្លោះខ្លាំងក្លាអំពីការអប់រំ។

ការកើនឡើងនៃវណ្ណៈពាណិជ្ជកម្មកណ្តាល និងរដ្ឋដែលជាជាតិដ៏ខ្លាំងនោះ រួមចំណែក ដល់ចលនាកំណែទម្រង់។ ទោះជាយ៉ាងណាក៏ដោយ អ្នកកែទម្រង់សាសនាប្រូតែស្តង់ជាលើកដំបូង ដែលរួមបញ្ចូលទាំង John Calvin, Martin Luther, Phillipe Melanchthon, and Ulrich Zwingli បានស្វែងរករំដោះខ្លួនគេ ហើយនិងសាវ័ករបស់គេ ពីអំណាចសម្តេចប៉ុប និងបកស្រាយលទ្ធិ និងការប្រតិបត្តិខាងសាសនាផ្ទាល់ខ្លួនរបស់គេ[12]។ នៅពេលដែលកំពុងធ្វើដូច្នេះ អ្នកកែទម្រង់ប្រូតែស្តង់ បានបង្កើតទ្រឹស្តីអប់រំផ្ទាល់ខ្លួនរបស់គេ បង្កើតសាលារៀនផ្ទាល់ខ្លួន រៀបចំរចនាសម្ព័ន្ធកម្មវិធីសិក្សា ចិញ្ចឹមកូនរបស់ពួកគេ តាមគោលជំនឿដែលបានកែទម្រង់។

### ខ-ការពង្រីកវិសាលភាពនៃអក្ខរកម្មដ៏មានប្រជាប្រិយ

Luther, Melanchthon, Calvin និងមេដឹកនាំកែទម្រង់ផ្សេងទៀត បានយកចិត្តទុកដាក់ ដោយខ្លួនគេ ជាមួយបញ្ហានៃចំណេះដឹង ការអប់រំ និងការសិក្សា ពីព្រោះពួកគេ ចង់ឱ្យអារ្យធម៌ មានឥទ្ធិពលទាំងនេះ ដើម្បីធ្វើឱ្យជឿនលឿនដល់បុព្វហេតុប្រូតែស្តង់។ ស្តីពីបញ្ហានៃចំណេះ

[11] Lucien Febvre and Henri-Jean Martin, *The Coming of the Book: The Impact of Printing, 1450-1800* (London: Verso, 1990).

[12] W. Robert Godfrey, Reformation Sketches: Insights into Luther, Calvin, and the Confessions (Phillipsburg, N.J: P&R Publishers, 2003).

ដឹង អំណាចកំពូលរបស់ពួកគេគឺព្រះគម្ពីរ (The Bible)។ ដោយចាត់ទុកការអានព្រះគម្ពីរថា ជារឿងចាំបាច់ដើម្បីការជួសជុលព្រលឹងនោះ អ្នកកែទម្រង់ប្រូតេស្តង់ បានជំរុញដល់សកលកម្មបឋមសិក្សា ដើម្បីធ្វើឱ្យមានភាពជឿនលឿនដល់អក្ខរកម្ម។

ពួកប្រូតេស្តង់ បានបង្កើតសាលារៀនភាសាតាមតំបន់ ដើម្បីបង្រៀនកុមារក្នុងភាសា ធម្មតារបស់គេ ដូចជា អាល្លឺម៉ង់ ស៊ុីស ស៊ុយអែត ឬអង់គ្លេស ជាជាងភាសាឡាតាំង។ សាលាបឋមសិក្សាទាំងនេះ ផ្តល់នូវកម្មវិធីសិក្សាជាមូលដ្ឋាននៃការអាន សរសេរ និងនព្វន្តសាស្ត្រ ព្រមទាំងសាសនា។ ប្រជាករខាងកាតូលិក និងការធ្វើសក្ការៈក្នុងព្រះវិហារ នៅតែជាភាសាឡាតាំងជាជាងភាសាក្នុងតំបន់ ទោះបីជាត្រូវប្រកួតប្រជែងជាមួយប្រូតេស្តង់ក៏ដោយ។ សាលារៀនកាតូលិក ក៏បានចាប់ផ្តើមរៀនភាសាក្នុងតំបន់ផងដែរ ស្របជាមួយភាសាឡាតាំង។

### គ-សន្ធនានិយមតាមបែបសាសនា

ទាំងសាសនាប្រូតេស្តង់ និងកាតូលិក បានប្រើប្រាស់សាលារៀន ដើម្បីអប់រំកុមារ ជាមួយនឹងជំនឿ និងការប្រតិបត្តិសាសនាដ៏ត្រឹមត្រូវ។ មានតែសមាជិកនៃព្រះវិហារ ដែលបាន អនុម័តិជាផ្លូវការទេ ដែលត្រូវបានគេជួលឱ្យធ្វើជាគ្រូ ហើយគ្រូត្រូវបានគេត្រួតពិនិត្យដោយយក ចិត្តទុកដាក់ដើម្បីធ្វើឱ្យប្រាកដថា ពួកគេបានបង្រៀនតាមលទ្ធិ ដែលបានយល់ស្របរួចហើយ។ ដើម្បីធានាដល់សមភាពខាងលទ្ធិ អ្នកអប់រំខាងសាសនា បានអភិវឌ្ឍវិធីបង្រៀន តាមគោលការណ៍សួរ និងឆ្លើយ។ នៅក្នុងទម្រង់សំណួរ និងចម្លើយ វាត្រូវបានសង្ខេបនូវលទ្ធិ និងការប្រតិបត្តិរបស់និកាយពិសេស។ ទោះបីជាការទន្ទេញតែងតែជារូបភាពមួយនៃការបង្រៀនក៏ដោយ វិធីចោទឆ្លើយ បានសង្កត់ធ្ងន់ទៅលើរឿងនេះ។ វត្ថុបំណង គឺត្រូវឱ្យកុមារទន្ទេញ តាមវិធីចោទ ឆ្លើយ និងដោយហេតុដូច្នេះហើយ ធ្វើឱ្យមានភាពជឿនលឿនខាងផ្នែកក្នុងនូវលទ្ធិនៃព្រះវិហាររបស់ពួកគេ។ ទម្រង់ចោទឆ្លើយ ទទួលបានឥទ្ធិពលយ៉ាងខ្លាំងទៅលើសាលារៀន ដែលវាត្រូវបានប្រើតាមមុខវិជ្ជា ដែលមិនទាក់ទងដល់សាសនាដូចជា ប្រវត្តិវិទ្យា និងភូមិវិទ្យា។

ឧ.វិធីចោទឆ្លើយ តាមបែបសាសនារបស់ខាល់វីន នៅព្រះវិហារហ្សឺណែវ (Geneva) បានប្រើវិធីចោទ និងឆ្លើយ៖

គ្រូៈ អ្វីជាគោលបំណងសំខាន់នៃជីវិតមនុស្ស?

សិស្សៈ ដើម្បីស្គាល់ព្រះ ដែលបានបង្កើតមនុស្ស។

នៅសតវត្សទី១៩ វិធីតែមួយ បាន បង្ហាញខ្លួនក្នុងប្រវត្តិរបស់ Davenport នៃ សហរដ្ឋអាម៉េរិកៈ

សំណួរៈ សង្គ្រាម នៅLexington បានកើតឡើងនៅពេលណា?

ចម្លើយៈ នៅថ្ងៃទី១៩ មេសា ១៧៧៥ ការបង្ហូរឈាមបាន កើតឡើងនៅទីនោះ ជាលើកដំបូងក្នុងបដិវត្តន៍ជនជាតិអាម៉េរិក[13]។

**ឃ-អក្ខរកម្មកំពុងតែមានការកើនឡើង**

ដោយមានការសង្កត់ធ្ងន់ទៅលើ អក្ខរកម្មដ៏មានប្រជាប្រិយ និងការកើនឡើងនូវការចូលរៀន នៅតាមសាលារៀន នោះ ការកែទម្រង់ប្រូតែស្តង់ បានចាប់ផ្តើមមានការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងការ អប់រំ និងក្នុងអត្រាអក្ខរកម្ម។

ឧទាហរណ៍ មានតែមនុស្សប្រុស ១០% និងស្ត្រី២%ប៉ុណ្ណោះ ក្នុងប្រទេស អង់គ្លេស ជាអក្ខរជន នៅឆ្នាំ១៥០០។ ត្រឹមឆ្នាំ១៦០០ បរិមាណនេះបានកើនឡើង ដល់២៨% ចំពោះបុរស និង៩% សម្រាប់ ស្ត្រី ហើយត្រឹមឆ្នាំ១៧០០ មានបុរសជិត ៤០% និងស្ត្រីប្រហែល៣២% ជាអក្ខរជន។

អត្រាអក្ខរជនមានកម្រិតខ្ពស់ នៅ អឺរ៉ុបខាងជើងជាងអឺរ៉ុបខាងត្បូង នៅតំបន់ ទីក្រុង ផ្ទុយគ្នាទៅនឹងតំបន់ជនបទ ហើយ អត្រានេះទៀតសោត មានកម្រិតខ្ពស់ ចំពោះពួកវណ្ណៈខ្ពស់ជាងវណ្ណៈទាប[14]។

**ខ-កំណើនការចូលរៀន**

តាមតួលេខខាងលើនេះ អ្នកកែទម្រង់ ចង់ឱ្យទាំងក្មេងប្រុស ទាំងក្មេងស្រី បានសិក្សា នៅសាលាបឋមសិក្សាភាសា ថ្នាក់តំបន់ ហើយការខិតខំប្រឹងប្រែងរបស់ គេ បានបង្កើនការចូល រៀននៅសាលា សម្រាប់គេទាំងពីរ។ ទោះជាយ៉ាងនេះក្តី អ្នកកែទម្រង់ប្រូតែស្តង់បានបន្ត បម្រើ ពួក មនុស្សនិយមក្លាស៊ីកនូវសាលាបឋម សិក្សាបង់ថ្លៃ និងសាលាមធ្យមសិក្សា សម្រាប់ក្មេងប្រុសវណ្ណៈខ្ពស់។ សាលា បឋមសិក្សា និងមធ្យមសិក្សាដូចជា ភាសា អាល្លឺម៉ង់ Gymnasium ដែលជាសាលា បឋមសិក្សាឡាតាំងអង់គ្លេស ហើយភាសា បារាំង Lycée បានត្រៀមរៀបចំ ក្មេងប្រុស ត្រកូលខ្ពស់ ជាភាសាឡាតាំង និងក្រិក ដែលជាភាសាក្លាស៊ិក ដែលចាំបាច់ សម្រាប់ចូលរៀននៅសាកលវិទ្យាល័យ។ វរជននេះ ត្រូវបានកំណត់ដោគវាសនា

---

[13] John Calvin, *Tracts nad Treatises on the Doctrine and Worship of the Church, II,* Translated by Henry Beveride (Grand Rapidd, MI: Wm. B. Erdmans Publishing Co., 1958) p. 37; and Bishop Davenport, *Histiry of the United States* (Philadelphia: William Marchall and Co. 1883), p. 31.

[14] Mary Jo Maynes, *Schooling in Western Europe: A Social History* (Albany: State University of New York Press 1985).

*សម្រាប់តួនាទី ជាអ្នក ដឹកនាំក្នុងព្រះវិហារ ឬរដ្ឋ។*

*មនុស្សដែលមានភាពល្បីល្បាញ ជាច្រើន ដូចជា* Calvin, Zwingli, Ignatius Loyola, and Henry VIII *សុទ្ធតែស្ថិតក្នុងចំណោម ពួកគេទាំងនេះ បានបង្កើតឥទ្ធិពល ទៅលើការកែទម្រង់និង ការកែទម្រង់តបទៅ ពួករ៉ូម៉ាំងកាតូលិក។* Martin Luther *ដែលជាជនជាតិអាល្លឺម៉ង់ គឺជាអ្នកកែទម្រង់ដែលនាំមុខគេ។*

### ៩ - ១ - Luther: អ្នកកែទម្រង់សាសនា នៅជាប្រូតែស្តង់

#### ក- Luther ប្រឆាំងព្រះវិហារកាតូលិក

Martin Luther(1483-1546) *លេចធ្លោក្នុងនាមជាអ្នកកែទម្រង់សាសនាដ៏សំខាន់បំផុតម្នាក់ ដោយបានបង្កើតប្រវត្តិសាស្ត្រ និងការអប់រំលោកខាងលិច*[15]*។ ក្នុងនាមជាព្រះសង្ឃ* Augustinian *មួយអង្គក្នុងប្រទេសអាល្លឺម៉ង់* Luther*បានបង្កើនការរិះគន់ទៅលើការប្រតិបត្តិពួកកាតូលិក។ ក្នុងឆ្នាំ ១៥១៧ នៅ*Wittenberg *គាត់បានដាក់ស្នើសំណើ៩៥ដ៏ល្បីល្បាញ នៅច្រកទ្វារនៃព្រះវិហារ ដែលជាប្រាសាទ ដោយបានប្រឆាំងនឹងព្រះវិហាររ៉ូម៉ាំងកាតូលិក និងសង្ឃរាជ វិហារកាតូលិក។ ការប្រឆាំងរបស់*Luther *គឺជាកត្តាលីករសម្រាប់ការកែទម្រង់ប្រូតែស្តង់ ដែលរាលដាលដល់អឺរ៉ុបបែកខាងលិច។*

#### ខ-ការអប់រំជាផ្នែកមួយនៃការកែទម្រង់សាសនា

Luther*បានទទួលស្គាល់ការអប់រំថាជាសម្ព័ន្ធមិត្ត ដ៏មានសក្តានុពលនៃការកែទម្រង់សាសនា។ គាត់យល់ថា ព្រះវិហារ រដ្ឋ គ្រួសារ និងសាលារៀន ជាភ្នាក់ងារកែទម្រង់ដ៏ចាំបាច់។ ដោយជឿជាក់ថា គ្រួសារមានតួនាទីដ៏សំខាន់ ក្នុងការបង្កើតអត្តចរិត និងអាកប្បកិរិយាកុមារ* Luther *បានលើកទឹកចិត្តអាន និងការសូត្រធម៌ តាមគម្ពីរនៅក្នុងគ្រួសារ។ គាត់ក៏ចង់ឱ្យឪពុក ម្តាយ មានការជឿជាក់ផងដែរថា កុមារបានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអាចឱ្យគេអាចទ្រទ្រង់ខ្លួនគេ នៅពេលក្លាយជាមនុស្សចាស់ ហើយក្លាយជាពលរដ្ឋមានប្រយោជន៍។*

#### គ-Luther ស្តីពីសាលារៀន

*សំបុត្រ*Luther *ចំពោះចៅហ្វាយក្រុង និងសមាជិកក្រុមប្រឹក្សាក្រុង* (Aldermen) *នៃទីក្រុងទាំងអស់ តាងនាមឱ្យសាលាគ្រិស្តទាំងឡាយ បានផ្តល់ដំបូន្មានឱ្យមន្ត្រីសាធារណៈ ដើម្បី ទទួលខុសត្រូវលើការអប់រំ និងសង្កត់ធ្ងន់ទៅលើ*

---

[15] Biographies of Luther are James A. Nestigen, *Martin Luther: A Life* (Minneapolis, Minn: Augsburg, 2003); Fredrick Nohl, *Luther: Biography of a Reformer* (St. Louis, Mo.: Concordia Publishing House, 2003); James M. Kittelson, *Luther: The Reformer* (Philadelphia: Penn.: Fortress, 2003).

ប្រយោជន៍នៃនយោបាយ សេដ្ឋកិច្ចនិង ស្មារតី នៃការសិក្សាអប់រំ។ Luther បានស្នើ ដោយទទូចថា សាលារៀន គួរតែត្រូវបាន រៀបចំ និងត្រួតពិនិត្យ ដោយមន្ត្រីរដ្ឋ ដើម្បី បណ្តុះបណ្តាលអក្ខរជន ឬរៀមច្បង និង ពលរដ្ឋដែលជាផលិតករ និងសមាជិកនៃ ព្រះវិហារ។ ការអប់រំជាន់ខ្ពស់នៅ សាលាGymnasium និងសាកលវិទ្យាល័យ នឹងត្រៀមរៀបចំរដ្ឋមន្ត្រីដែលមានការអប់រំ ល្អ សម្រាប់ព្រះវិហារ Lutheran។

**ឃ- Luther ស្តីពីការអប់រំស្ត្រី**

ទស្សនៈរបស់ Lutherស្តីពីការអប់រំ ស្ត្រី ឆ្លុះបញ្ចាំងភាពតឹងរ៉ឹងទៅតាម ប្រពៃណី តែក៏មាន គំនិតសេរីផងដែរ។ ដោយបានទទួលឥទ្ធិពលពី Saint Paul គាត់ជឿជាក់ថា ស្វាមី ដែលជាមេគ្រួសារ មានអំណាចទៅលើភរិយា។ តួនាទីក្នុងផ្ទះ និងការចិញ្ចឹមកូន នៅតែជាតួនាទីដ៏សម រម្យរបស់ស្ត្រី។ ម្យ៉ាងវិញទៀត ការបញ្ជាក់ អះអាងរបស់ Luther ទៅលើការអានព្រះ គម្ពីរ តាមភាសាផ្ទាល់របស់ខ្លួន មានន័យ ថា ក្មេងស្រី ព្រមទាំងក្មេងប្រុសត្រូវទៅ រៀននៅសាលាប ឋមសិក្សា ដូច្នោះហើយ ការសិក្សា ផ្តល់ឱ្យស្ត្រីនូវតួនាទីបន្ទាប់បន្សំ និងតាមផ្នែកក្នុងការអប់រំកូនរបស់ពួកគេ។

**ខ-គោលការណ៍សាលារៀន**

ដើម្បីរៀបចំ និងអនុវត្តការកែ ទម្រង់អប់រំ Luther បានពឹងផ្អែកជាខ្លាំងទៅ លើ Philipp Melanch- thon(1497-1560)។ ដើម្បីស្វែងរកការបញ្ចប់ការគ្រប់គ្រង របស់សាលារៀនរ៉ូម៉ាំងកាតូលិក ទៅលើ សាលារៀននោះ Luther and Melanchthon ចង់ឱ្យរដ្ឋត្រួតពិនិត្យទៅលើសាលារៀន និងផ្តល់លិខិតបញ្ជាក់ដល់គ្រូ។ នៅឆ្នាំ ១៥៥៩ Melanchthon បានព្រាងគោល ការណ៍សាលារៀន Wurtemberg ដែលបាន ក្លាយជាគំរូមួយសម្រាប់រដ្ឋអាល្លឺម៉ង់ផ្សេង ទៀត។ គោលការណ៍នោះ បានបញ្ជាក់ យ៉ាងជាក់លាក់ នូវសាលារៀនបឋម សិក្សាភាសាក្នុងតំបន់ នៅគ្រប់ភូមិ ដើម្បី បង្រៀនសាសនា ការអាន ការសរសេរ នព្វន្តសាស្ត្រ និងតន្ត្រី។ សាលាមធ្យម សិក្សាក្វាស៊ីក (Gymnesien)ត្រូវផ្តល់ការ បង្រៀនភាសាក្រិក និងឡាតាំង សម្រាប់ អ្នកទាំងឡាយដែលជ្រើសរើសមនុស្សក្មេងៗ ដែលបានរំពឹងថា នឹងត្រូវចូលរៀននៅ សាកលវិទ្យាល័យ។

**៩-២-ការរួមចំណែកនៃការកែទម្រង់ ដល់ការអប់រំនៅលោកខាងលិច**

កំណែទម្រង់ប្រូតែស្តង់ បាន អះអាងឡើងវិញ នូវការអភិវឌ្ឍស្ថាប័នជា ច្រើនពីបុនសម័យ ជាពិ សេសប្រព័ន្ធទ្វេ នៃសាលារៀន។ នៅពេលដែលសាលា រៀន ដែលប្រើភាសាក្នុងតំបន់ បានផ្តល់ ការបង្រៀននៅបឋមសិក្សាដល់វណ្ណៈ

សេដ្ឋកិច្ចសង្គមកម្រិតទាប ដែលជាសាលារៀនបឋមសិក្សាមនុស្សនិយមក្វាស៊ីកផ្សេងៗ បានរៀបចំវណ្ណៈខ្ពស់ សម្រាប់ឧត្តមសិក្សា។ ពួកអាណានិគមអឺរ៉ុប ជាបន្តបន្ទាប់ បាននាំនូវសាលារៀនតាមប្រព័ន្ធទ្វេ ទៅដល់ពិភពលោកថ្មី។

តាមរយៈការបញ្ជាក់ន័យ ទៅលើការអានព្រះគម្ពីរនោះ អ្នកកែទម្រង់ប្រូតែស្តង់ ក៏បានទុកកេរ្តិ៍ឱ្យអ្នកអប់រំជំនាន់ក្រោយ នូវការបញ្ជាក់ន័យដ៏សំខាន់ទៅលើអក្ខរកម្ម។ សកម្មភាពនេះ ជួយបង្កើនល្បឿនចលនាឆ្ពោះទៅកាន់ការអប់រំសកល។

***សាសនា មានឥទ្ធិពលដ៏ធំធេង ទៅលើការអប់រំ និងការសិក្សា ពីសម័យកាលបុរាណ ទៅកាន់សតវត្សទី២១។*** សាលារៀនជាច្រើន បានផ្សារភ្ជាប់ទៅនឹងព្រះវិហារ វត្ត និងព្រះវិហារកាតូលិក។ នៅសហរដ្ឋអាម៉េរិក សាលារៀន សាលាវិជ្ជាជីវៈ និងមហាវិទ្យាល័យសម័យដើម បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសាសនា។ ថ្មីៗនេះមានសិស្សសាលាបឋមនិងមធ្យមសិក្សា ប្រហែល៤,៣៩៤,៤២០នាក់ កំពុងសិក្សានៅសា លារៀន ដែលពាក់ព័ន្ធដល់សាសនា[16]។

ទោះជាយ៉ាងណាក៏ដោយ នៅសតវត្សទី១៨ ឥទ្ធិពលសាសនាទៅលើការអប់រំ បានពើបប្រទះនឹងការប្រឆាំង។ ធម្មជាតិនិយម និងវិចារណញ្ញាណនិយម នៃជំនឿសមហេតុផល និង វិទ្យាសាស្ត្រ ដែលជាយុគសម័យគិតពីហេតុផល បានរាលដាលពាសពេញទ្វីបអឺរ៉ុប។

## ១០-ឥទ្ធិពលនៃជំនឿប្រកបដោយវិចារណញ្ញាណ និងវិទ្យាសាស្ត្រ នៅលើការអប់រំ

នៅពេលដែលយើងពិនិត្យមើលយុគសម័យជំនឿសមហេតុផល និងវិទ្យាសាស្ត្រ នាសតវត្សទី១៨ (ក៏ត្រូវបានគេហៅថា យុគសម័យនៃវិចារណញ្ញាណ) ចូរចាំថា ស្ថាប័ននយោបាយសហរដ្ឋអាម៉េរិក គឺជាផលិតផលនៃសករាជនោះ។ គំនិតវិចារណញ្ញាណ និងវិទ្យាសាស្ត្រ បានជះឥទ្ធិពលដល់អ្នកកែទម្រង់អប់រំយ៉ាងចម្បង ដូចជា Rousseau, Pestalozzi, and Froebel។ គំនិតនៃអ្នកកែទម្រង់អឺរ៉ុប បានរាលដាលដល់ទ្វីបអាម៉េរិក។

### ក-វិចារ និងវិធីវិទ្យាសាស្ត្រ

គំនិតប្រកបដោយវិចារណញ្ញាណ និងវិទ្យាសាស្ត្រដ៏ល្បីល្បាញ គឺឥទ្ធិពលនៃវិចារណញ្ញាណ។ ទស្សនវិទូ អ្នកវិទ្យាសាស្ត្រ និងវិជ្ជាករទាំងនេះ បានជឿជាក់យ៉ាងខ្លាំងថា មនុស្សអាចកែលំអជីវិត និងស្ថាប័នរបស់ពួកគេ តាមការប្រើ

[16] Private School Universe Survey, 1999-2000; **http:nces.ed.gov/pubsearch**/(01/12/2003).

ប្រាស់វិចារណញ្ញាណ ដើម្បីដោះស្រាយបញ្ហា[17]។ ដោយសង្កត់ធ្ងន់ទៅលើការអង្កេតបែបវិទ្យាសាស្ត្រនោះ អ្នកផ្តើមគំនិតទាំងនេះ បានប៉ុនប៉ងរកឱ្យឃើញ "ច្បាប់ធម្មជាតិ" លំនាំតាមលំដាប់លំដោយដែលធម្មជាតិមានមុខងារ។ ពួកគេក៏បានប្រឌិតទ្រឹស្តីកំណែទម្រង់សង្គម។

ឧទាហរណ៍: មនោគមវិជ្ជា ដែលមានមូលដ្ឋានលើបដិវត្តន៍អាម៉េរិក និងបារាំងបានស្វែងរកដើម្បីស្ថាបនាឡើងវិញនូវសណ្តាប់ធ្នាប់នយោបាយ យោងទៅតាមវិចារណញ្ញាណ។

មនោគមវិជ្ជាវិចារណញ្ញាណ និងវិទ្យាសាស្ត្រ បានបញ្ជាក់ថា សាលារៀនគួរតែបណ្តុះបំណិនសិស្ស ដើម្បីធ្វើវិចារ និងរំដោះខ្លួនគេឱ្យចេញផុតពីជំនឿឆ្វេងហួសហេតុ។

**ខ-ជំនឿក្នុងការអភិវឌ្ឍ**

មនុស្សដែលមានវិចារណញ្ញាណ និងវិទ្យាសាស្ត្រគួរឱ្យកត់សម្គាល់ មានដូចជា Diderot, Rous- seau, Franklin, and Jefferson បានមើលឃើញមនុស្សជាតិ ថាជាការឈានឆ្ពោះទៅមុខ ចំពោះពិភពលោកថ្មី និងប្រសើរជាងមុន។ ពួកគេលែងត្រូវការសម្លឹងមើលត្រឡប់ទៅក្រោយ ទៅយុគមាសរបស់ក្រិកឬរ៉ូមទៀតហើយ។ ដោយប្រើប្រាស់វិចារណញ្ញាណ និងវិធីវិទ្យាសាស្ត្រ មនុស្សអាចសម្រេចបាននូវការអភិវឌ្ឍ នៅលើភពផែនដី។ សាលារៀនត្រូវតែជាស្ថាប័ន មានការរីកចម្រើន ដែលលើកទឹកចិត្តសិស្ស ឱ្យអភិវឌ្ឍឥរិយាបថដែលចេះសួរ ចិត្ត ទូលាយ និងភាពចង់ចេះដឹង ដើម្បីប្រើប្រាស់វិធីសង្កេតពិសោធបែបវិទ្យាសាស្ត្រ។

គំនិតប្រកបដោយវិចារណញ្ញាណ និងវិទ្យាសាស្ត្រ បានចាប់កំណើតនៅសហរដ្ឋអាម៉េរិក ដែលជាកន្លែងដែលពួកគេបានអភិវឌ្ឍ ទៅជាជំនឿប្រកបដោយសុទិដ្ឋិនិយមក្នុង នយោបាយប្រជាធិបតេយ្យ និងសកលកម្មការអប់រំ។ ពួកគេបានអនុវត្តតាមគំនិតរបស់លោក Benjamin Franklin ស្តីពីការអប់រំដែលមានប្រយោជន៍ និងបែបវិទ្យាសាស្ត្រ និងការអះអាងរបស់ Thomas Jefferson សម្រាប់សាលារៀនដែលគាំទ្រដោយរដ្ឋ។ ដោយបានជឿជាក់ពីបំណិនរបស់គេដើម្បីដឹកនាំអនាគតខ្លួនគេ ជនជាតិអាម៉េរិក បានយល់ឃើញថា ការអប់រំជាគន្លឹះ សម្រាប់ការអភិវឌ្ឍ (Education as the key to progress)[18]។

[17] Ulrich Im Hoff, The Enlightenment (Cambridge, Mass.: Basli Blackwell, 1994).

[18] Daniel Feller, The Jacksonian Promise: America, 1815-1840 (Baltimore: Johns Hopkins University Press, 1995), pp viii-xiv.

**១១-ការសង្ខេប: រយៈពេលជាគន្លឹះក្នុងប្រវត្តិអប់រំ**

**ក-សង្គមបុរេអក្សរកម្ម**(**៧000-៥000 មុនគ.ស.**)

1-គោលដៅអប់រំ៖ បង្រៀនបំណិនគង់នៅរបស់ក្រុម និងភាពពាក់ព័ន្ធរបស់ក្រុម។

2-សិស្ស៖ កុមារនៅក្នុងក្រុម។

3-វិធីបង្រៀន៖ ការបង្រៀនមិនផ្លូវការ កុមារត្រាប់តាមមនុស្សចាស់នូវបំណិន និងតម្លៃ។

4-កម្មវិធីសិក្សា៖ បំណិនគង់នៅនៃការប្រមាញ់ នេសាទ ការប្រមូលផ្តុំអាហារ រឿងនិទាន ជំនឿសាមញ្ញ ចម្រៀងកំណាព្យ និងរបាំ។

5-ភ្នាក់ងារ៖ មាតាបិតា រៀមច្បងក្នុងកុលសម្ព័ន្ធ និងបព្វជិត។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការសង្កត់ធ្ងន់ទៅលើការអប់រំមិនផ្លូវការ ដើម្បីផ្ទេរបំណិន និងតម្លៃ។

**ខ-ចិន**(**៣000 មុនគ.ស.-១៩00 គ.ស.**)

1-គោលដៅអប់រំ៖ ត្រៀមរៀបចំមន្ត្រីដែលជាវរជន ដើម្បីគ្រប់គ្រងចក្រភពដោយយោងទៅតាមគោលការណ៍ខុងជឺ។

2-សិស្ស៖ មនុស្សប្រុស ដែលមានវណ្ណៈខ្ពស់។

3-វិធីបង្រៀន៖ ការទន្ទេញ និងការសូត្រអត្ថបទបែបបុរាណ។

4-កម្មវិធីសិក្សា៖ គំរូតាមខុងជឺ។

5-ភ្នាក់ងារ៖ មន្ត្រីរដ្ឋាភិបាល។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការប្រឡងបែបសរសេរ សម្រាប់សេវាកម្មស៊ីវិល និងវិជ្ជាជីវៈផ្សេងទៀត។

**គ-ឥណ្ឌា** (**៣000-មុនគ.ស.-បច្ចុប្បន្ន**)

1-គោលដៅអប់រំ៖ សិក្សាអាកប្បកិរិយា និងទម្លាប់ដោយផ្អែកលើគម្ពីរវេទ។

2-សិស្ស៖ មនុស្សប្រុស ដែលមានវណ្ណៈខ្ពស់។

3-វិធីបង្រៀន៖ ការទន្ទេញ និងបកប្រែគម្ពីរពិសិដ្ឋ។

4-កម្មវិធីសិក្សា៖ អត្ថបទសាសនា និងគម្ពីរវេទ។

5-ភ្នាក់ងារ៖ វិជ្ជាករដែលជាបព្វជិតព្រាហ្មណ៍។

6-ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការផ្ទេរ និងការជ្រួតជ្រាបវប្បធម៌ភាពដោយឡែកខាងស្មារតី។

**ឃ-អេហ្ស៊ីប** (**៣000-៣00 មុនគ.ស.**)

1-គោលដៅអប់រំ៖ ត្រៀមរៀបចំមនុស្សឱ្យចេះកត់ត្រាអក្សរ ដែលបព្វជិតបានបង្រៀន ដើម្បីគ្រប់គ្រងចក្រភព។

2-សិស្ស៖ មនុស្សប្រុស ដែលមានវណ្ណៈខ្ពស់។

3-វិធីបង្រៀនៈ ទន្ទេញ និងការចម្លងអត្ថបទ ដែលគេហៅឱ្យកត់ត្រា។

4-កម្មវិធីសិក្សាៈ អត្ថបទខាងបច្ចេកទេស ឬសាសនា។

5-ភ្នាក់ងារៈ បព្វជិត និងអ្នករៀនកត់ត្រាអក្សរ។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ ភាពរឹតបន្តឹងនៃការគ្រប់គ្រងអប់រំ និងសេវាកម្ម ដល់វរជនដែលជាបព្វជិត ប្រយោជន៍នៃការអប់រំ ដើម្បីត្រៀមរៀបចំការិយាធិបតេយ្យ។

**ខ-ក្រិក** (**១៦០០-៣០០ មុនគ.ស.**)

1-គោលដៅអប់រំៈ

-អាថែនៈ បណ្តុះការទទួលខុសត្រូវនៃពលរដ្ឋ និងកំណត់អត្តសញ្ញាណជាមួយទីក្រុងដែលជារដ្ឋ និងដើម្បីអភិវឌ្ឍមនុស្សដែលល្អគ្រប់ជ្រុងជ្រោយ។

-ស្ប៉ាតៈ បណ្តុះបណ្តាលទាហាន និងមេដឹកនាំកងទ័ព។

2-សិស្សៈ កុមារ និងមនុស្សប្រុសដែលជាពលរដ្ឋ មានអាយុពី៧-២០ ឆ្នាំ។

3-វិធីបង្រៀនៈ ហ្វឹកហាត់ ទន្ទេញសូត្រ នៅសាលាបឋមសិក្សា បង្រៀនពិភាក្សា និងសន្ទនា នៅមធ្យមសិក្សា។

4-កម្មវិធីសិក្សាៈ

-អាថែនៈ ការអាន សរសេរ នព្វន្តសាស្ត្រ វិនាដសាស្ត្រ តន្ត្រី អប់រំកាយ អក្សរសិល្ប៍ កំណាព្យ។

-ស្ប៉ាតៈ ហ្វឹកហាត់ ចម្រៀងកងទ័ព និងយុទ្ធវិធី។

5-ភ្នាក់ងារៈ

-អាថែនៈ សាលា និងគ្រូបង្រៀនឯកជន ពួកសូហ្វីស ទស្សនវិទូ។

-ស្ប៉ាតៈ មន្ត្រីកងទ័ព។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ

-អាថែនៈ បញ្ញត្តិនៃមនុស្ស ដែលមានការអប់រំសេរីល្អគ្រប់ជ្រុងជ្រោយ

-ស្ប៉ាតៈ បញ្ញត្តិនៃការបម្រើរដ្ឋដែលជាកងទ័ព។

**គ-រ៉ូម៉ាំង** (**៧៥០មុនគ.ស.-៤៥០ នៃគ.ស.**)

1-គោលដៅអប់រំៈ អភិវឌ្ឍការទទួលខុសត្រូវរបស់ពលរដ្ឋ សម្រាប់សាធារណរដ្ឋ ហើយបន្ទាប់មកចក្រភពអភិវឌ្ឍបំណិនរដ្ឋបាល និងកងទ័ព។

2-សិស្សៈ កុមារ និងមនុស្សប្រុសដែលមានវណ្ណៈខ្ពស់ អាយុ៧-២០ឆ្នាំ។

3-វិធីបង្រៀនៈ ហ្វឹកហាត់ ទន្ទេញសូត្រ នៅសាលាកម្រិតទាប ការនិយាយថ្លែងទៅកាន់ទស្សនិកជន ក្នុងសាលាកម្រិតខ្ពស់។

4-កម្មវិធីសិក្សាៈ ការអាន ការសរសេរ នព្វន្តសាស្ត្រ ច្បាប់តារាង១២ច្បាប់ទស្សនវិជ្ជា។

5-ភ្នាក់ងារៈ សាលាឯកជន និងគ្រូបង្រៀន សាលាវោហារសាស្ត្រ។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ សង្កត់ធ្ងន់ទៅលើការអប់រំ សម្រាប់បំណិន រដ្ឋបាល ជាក់ស្តែង ទំនាក់ទំនងការអប់រំ ទៅនឹងការទទួលខុសត្រូវរបស់ពលរដ្ឋ។

**ឆ-អារ៉ាប់** (**៧០០-១៣៥០ នៃគ.ស.**)

1-គោលដៅអប់រំៈ បណ្តុះការតស៊ូ ប្តូរផ្តាច់ ចំពោះជំនឿសាសនាអ៊ីស្លាម អភិវឌ្ឍអ្នកជំនាញខាងគណិតវិទ្យា វេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ។

2-សិស្សៈ កុមារ និងមនុស្សប្រុស ដែលមានវណ្ណៈខ្ពស់ អាយុ៧-២០ឆ្នាំ។

3-វិធីបង្រៀនៈ ហ្វឹកហាត់ ទន្ទេញសូត្រ នៅសាលាកម្រិតទាប ត្រាប់តាម និង ពិភាក្សា និងសន្ទនា នៅសាលាកម្រិតខ្ពស់។

4-កម្មវិធីសិក្សាៈ ការអាន ការសរសេរ គណិតវិទ្យា អក្សរសាស្ត្រខាងសាសនា ការសិក្សាខាងវិទ្យាសាស្ត្រ។

5-ភ្នាក់ងារៈ ព្រះវិហារម៉ូស សាលារៀនវាំង។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ លេខអារ៉ាប់ និងការគិតលេខ ការបញ្ចូលសម្ភារបែបបុរាណ ចំពោះវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ។

**ជ-មជ្ឈិមសម័យ** (**៥០០-១៤០០ គ.ស.**)

1-គោលដៅអប់រំៈ អភិវឌ្ឍការតស៊ូ ប្តូរផ្តាច់ ចំពោះសាសនា ចំណេះដឹង និងទម្លាប់ ត្រៀមរៀបចំមនុស្ស សម្រាប់តួនាទីសមរម្យ តាមឋានានុក្រម។

2-សិស្សៈ ក្មេងប្រុសវណ្ណៈខ្ពស់ ឬ អ្នកទាំងឡាយដែលកំពុងចូលរួមជីវិតសាសនា ក្មេងស្រី និងស្ត្រីក្មេងៗ ដែលកំពុងចូលរួមសហគមន៍សាសនា ពីអាយុ ៧-២០ឆ្នាំ។

3-វិធីបង្រៀនៈ ហ្វឹកហាត់ ទន្ទេញសូត្រ ស្មូត្រ នៅសាលាកម្រិតទាប ការវិភាគអត្ថបទ និងការពិភាក្សាជាផ្លូវការ នៅសាលាកម្រិតខ្ពស់ និងសាកលវិទ្យាល័យ។

4-កម្មវិធីសិក្សាៈ ការអាន ការសរសេរ នព្វន្តសាស្ត្រ សិល្បៈសេរី ទស្សនវិជ្ជា ការប៉ិនប្រសប់ យុទ្ធ សាស្ត្រយោធា និងភាពជាអ្នកក្លាហានប្រកបដោយសីលធម៌។

5-ភ្នាក់ងារៈ សាលារៀនជើងវត្ត ច្រៀងចម្រៀងជាពួក និងព្រះវិហារ សាកលវិទ្យាល័យ ភាពជាអ្នកហាត់ការអស្សប្ញទ្ធិភាព។

6-ឥទ្ធិពលទៅលើការអប់រំទំនើបៈ រចនាសម្ព័ន្ធដែលបានបង្កើតឡើង ខ្លឹមសារ និងការចាត់តាំងសាកលវិទ្យាល័យ ជាស្ថាប័នចម្បងនៃឧត្តមសិក្សាស្ថាប័ននីយកម្ម និងការរក្សាទុកចំណេះដឹង។

**ឈ-មុនសម័យ** (**១៣៥០-១៥០០ គ.ស.**)

1-*គោលដៅអប់រំ៖ បណ្តុះអ្នកជំនាញការមនុស្សនិយម ក្នុងអក្សរសិល្ប៍ក្រិក និងឡាតាំង ត្រៀមរៀបចំបរិវារស្តេចសម្រាប់សេវាកម្ម ចំពោះមេដឹកនាំសន្តិវង្សា*

2-*សិស្ស៖ ក្មេងប្រុសនៃវណ្ណៈអភិជន និងវណ្ណៈខ្ពស់ អាយុ៧-២០ឆ្នាំ។*

3-*វិធីបង្រៀន៖ ការទន្ទេញ ការបកប្រែ និងការវិភាគអក្សរសិល្ប៍ក្រិក និងរ៉ូម៉ាំង។*

4-*កម្មវិធីសិក្សា៖ភាសាក្រិកឡាតាំង អក្សរសិល្ប៍ កំណាព្យ សិល្បៈ។*

5-*ភ្នាក់ងារ៖ អ្នកអប់រំមនុស្សនិយម និងសាលាដូចជា វិទ្យាល័យ និងសាលាភាសា ឡាតាំង។*

6-*ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការសង្កត់ធ្ងន់ទៅលើចំណេះអក្ខរកម្ម ឧត្តមភាព និងរចនាបថដែលបានបង្ហាញក្នុង អក្សរសិល្ប៍ក្រិក និងឡាតាំង និងប្រព័ន្ធពីរបែបនៃសាលារៀន។*

**ឈ-សម័យការកែទម្រង់** (**១៥០០-១៦០០ គ.ស.**)

1-*គោលដៅអប់រំ៖ បំពាក់បំប៉នការតស៊ូសន្យា ដល់និកាយសាសនា ពិសេសបណ្តុះអក្ខរកម្មទូទៅ។*

2-*សិស្ស៖ ក្មេងប្រុស និងស្រី អាយុពី៧-១២ឆ្នាំ នៃសាលារៀនក្នុងតំបន់ណាមួយ ក្មេងប្រុសអាយុពី ៧-១២ ដែលមានប្រវត្តិវណ្ណៈខ្ពស់ក្នុងសាលាមនុស្សនិយម។*

3-*វិធីបង្រៀន៖ ទន្ទេញ ហ្វឹកហាត់ការបញ្ចុះបញ្ចូលឱ្យធ្វើតាម ការបង្រៀនតាមព្រះវិហារ ក្នុងសាលារៀន នៅតំបន់ណាមួយ ការបកប្រែ វិភាគអក្សរសិល្ប៍ក្រិក និងឡាតាំង ក្នុងសាលាមនុស្សនិយម។*

4-*កម្មវិធីសិក្សា៖ ការអាន សរសេរ នព្វន្តសាស្ត្រ ការសង្ខេបគោលការណ៍សាសនា បញ្ញត្តិសាសនា និងទម្លាប់សាសនវិទ្យាក្រិក និងឡាតាំង។*

5-*ភ្នាក់ងារ៖ សាលាបឋមសិក្សាក្នុងតំបន់ណាមួយ សម្រាប់ប្រជាករ សាលាបែបបុរាណ សម្រាប់ត្រកូលខ្ពស់។*

6-*ឥទ្ធិពលទៅលើការអប់រំទំនើប៖ ការតស៊ូសន្យា ចំពោះការអប់រំសកលដើម្បីផ្តល់ អក្សរ ដល់ប្រជាករ ប្រភពនៃប្រព័ន្ធសាលារៀន ជាមួយការត្រួតពិនិត្យដើម្បីជានាការអនុលោមទៅតាមលទ្ធិប្រព័ន្ធសាលាពីរបែប ដោយផ្អែកទៅលើវណ្ណៈ សេដ្ឋកិច្ចសង្គម និងគោលដៅវិជ្ជាជីវៈ។*

**១២-ទ្រឹស្តីវិធីអប់រំចម្បងៗដល់ឆ្នាំ១៦០០នៃគ.ស.**

**ក-ខុងជឺ ៥៥១-៤៧៨ មុនគ.ស.** (**ចិន**)

**1-*ការតម្រង់ទិសខាងទស្សនវិជ្ជា***

-បានអភិវឌ្ឍប្រព័ន្ធសីលវិទ្យា ដោយផ្អែកលើការរៀបចំទៅតាមឋានានុក្រម នៃទំនាក់ទំនងមនុស្ស និងតួនាទី។

-សង្កត់ធ្ងន់ទៅលើរបៀបរៀបរយ និងស្ថិរភាពតាមរយៈការនៅក្រោមបង្គាប់។

**2-ទស្សនៈធម្មជាតិមនុស្ស**

មនុស្សជាតិ ត្រូវការសណ្តាប់ធ្នាប់នៃសង្គម ដែលមានស្ថិរភាពកម្រិតខ្ពស់ ក្នុងនោះ មនុស្សទទួលយកករណីកិច្ច ដែលគិតដល់ឋានៈក្នុងជីវិត។

**3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**

-ការអប់រំត្រៀមរៀបចំមនុស្សសម្រាប់តួនាទីនយោបាយសង្គម តាមការបណ្តុះ**គរុការភាព** (Reve- rence) សម្រាប់បុព្វបុរស និងប្រពៃណី។

-កម្មវិធីសិក្សារបស់អ្នកនិពន្ធចិនបុរាណដែលមានគុណសម្បត្តិ និងតម្លៃអមតៈ និងការប្រមូលផ្តុំនៃអ្នកជំនាញការពីស្នាដៃអក្សរសិល្ប៍ (Analects) របស់ខុងជឺ។

-ការប្រឡងជ្រើសរើសកម្រិតខ្ពស់។

**4-ការរួមចំណែក និងឥទ្ធិពល**

ក្រុមសីលវិទ្យារបស់ខុងជឺបានបង្កើតវប្បធម៌ចិនអស់រយៈពេលជាច្រើនសតវត្សដោយ បានបង្កើតប្រព័ន្ធតម្លៃ ដែលនៅស្ថិតស្ថេរដ៏មានសារៈសំខាន់។

**ខ-សូក្រាត ៤៦៩-៣៩៩ មុនគ.ស** .(**ក្រិក**)

**1-ការតម្រង់ទិសខាងទស្សនវិជ្ជា**

អ្នកបំផ្លាញជំនឿសាសនា មានភាពលំអៀងទៅរកឧត្តមគតិនិយមទស្សនវិជ្ជា និងអភិរក្សនិយមនយោបាយ។

**2-ទស្សនៈស្តីពីធម្មជាតិមនុស្ស**

មនុស្សជាតិ អាចកំណត់ខ្លួនឯងបានតាមការពិនិត្យទៅលើខ្លួនឯងប្រកបដោយវិចារណញ្ញាណ។

**3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**

-ប្រើប្រាស់ការស្វែងរកការសន្ទនាប្រកបដោយភាពឈ្លាសវៃ ដើម្បីឆ្លើយទៅនឹងការយកចិត្តទុកដាក់របស់មនុស្សជាមូលដ្ឋាន។

-ការអប់រំ គួរតែបណ្តុះឧត្តមភាពខាងសីលធម៌។

**4-ការរួមចំណែក និងឥទ្ធិពល**

-ការសន្ទនា តាមបែបសូក្រាត ជាវិធីបង្រៀន។

-គ្រូ មានតួនាទីជាគំរូ។

**គ-ប្លាតុង ៤២៧-៣៤៦ មុនគ.ស.** (**ក្រិក**)

**1-ការតម្រង់ទិសខាងទស្សនវិជ្ជា**

*អ្នកមានឧត្តមគតិផ្នែកទស្សនវិជ្ជា អ្នកអភិរក្សផ្នែកនយោបាយសង្គម។*

***2-ទស្សនៈស្ដីពីធម្មជាតិមនុស្ស***

*មនុស្សជាតិ អាចត្រូវបានគេចាត់ថ្នាក់ទៅតាមមូលដ្ឋាននៃសមត្ថភាពបញ្ញា។*

***3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា***

*-ការសំណេះសំណាលពីគំនិតដែលមិនទាន់បង្ហាញឱ្យឃើញ។*

*-តន្ត្រី កីឡាកាយសម្ព័ន្ធ ធរណីមាត្រសាស្ត្រ តារាសាស្ត្រ បំណិនខាងអក្សរសិល្ប៍ជាមូលដ្ឋាន។*

*-ទស្សនវិជ្ជា សម្រាប់គ្រប់គ្រងវរជននៃអធិរាជខាងទស្សនវិជ្ជា។*

***4-ការរួមចំណែក និងឥទ្ធិពល***

*-ប្រើប្រាស់សាលារៀនទៅតាមប្រភេទសិស្ស យោងទៅតាមសមត្ថភាពបញ្ញា។*

*-កាអប់រំ ត្រូវផ្សារភ្ជាប់ទៅនឹងគោលបំណង(នយោបាយ)ពលរដ្ឋ។*

**ឃ-អារីស្តូត ៣៨៤-៣២២ មុន គ.ស. (ក្រិក)**

***1-ការតម្រង់ទិសខាងទស្សនវិជ្ជា***

*-អ្នកមានគំនិតតថៈខាងផ្នែកទស្សនវិជ្ជា។*

*-ទស្សនៈនៃសង្គមនយោបាយ និងការអប់រំ ដោយផ្អែកលើតថនិយមក្លាស៊ីក។*

***2-ទស្សនៈស្ដីពីធម្មជាតិមនុស្ស***

*មនុស្សជាតិ មានអំណាចប្រកបដោយវិចារណញ្ញាណ ដែលគួរតែបង្ហាញផ្លូវចរិយារបស់គេ។*

***3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា***

*-ការសង្កត់ធ្ងន់ទៅលើខាងវិទ្យាសាស្ត្រ និងជាសត្យានុម័តិ។*

*-បំណិនខាងអក្សរសាស្ត្រជាមូលដ្ឋាន គណិតវិទ្យា វិទ្យាសាស្ត្រធម្មជាតិ និងរាងកាយ ទស្សនវិជ្ជា។*

***4-ការរួមចំណែក និងឥទ្ធិពល***

*-ការសង្កត់ធ្ងន់លើមនុស្សដែលល្អគ្រប់ជ្រុងជ្រោយមានការអប់រំផ្នែកអក្សរសាស្ត្រ។*

*-សារៈសំខាន់នៃវិចារណញ្ញាណ។*

**ខ-អ៊ីសូក្រាត ៤៣៦-៣៨៨ មុន គ.ស. (ក្រិក)**

***1-ការតម្រង់ទិសខាងទស្សនវិជ្ជា***

*វោហារសាស្ត្រវិទូ ការអប់រំសិល្បៈនៃការថ្លែងសុន្ទរកថា ក្នុងសេវាកម្មដោយខ្លួនឯង និងសង្គម។*

***2-ទស្សនៈស្ដីពីធម្មជាតិមនុស្ស***

*មនុស្សមានថាមពល ដើម្បីប្រើប្រាស់ពាក្យសម្ដី សម្រាប់ការកែលំអនយោបាយ និងសង្គម។*

***3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា***

ការសិក្សាវោហារសាស្ត្រ បំណិន អក្សរសាស្ត្រជាមូលដ្ឋាន នយោបាយ ប្រវត្តិសាស្ត្រ ការថ្លែងទៅកាន់ទស្សនិកជន និងការនិយាយ នៅក្នុងទីសាធារណៈ។

**4-ការរួមចំណែក និងឥទ្ធិពល**

-ប្រើប្រាស់ចំណេះដឹងក្នុងកិច្ចការសាធារណៈ និងក្នុងមគ្គុទ្ទេសក៍ភាពនយោបាយ។

-ការអប់រំគ្រូ មានទាំងវិសាលភាព ខ្លឹមសារ និងការប្រតិបត្តិ។

**ច-ឃ្វីនធីលាន ៣៥-៩៥ នៃគ.ស. (រ៉ូម៉ាំង)**

**1-ការតម្រង់ទិសខាងទស្សនវិជ្ជា**

វោហារសាស្ត្រវិទូ សិល្បៈក្នុងការថ្លែងសុន្ទរកថា សម្រាប់គុណប្រយោជន៍បុគ្គល និង សេវាកម្មសាធារណៈ។

**2-ទស្សនៈស្ដីពីធម្មជាតិមនុស្ស**

បុគ្គលពិតប្រាកដ មានសមត្ថភាពសម្រាប់ដឹកនាំ ដោយផ្អែកលើអារម្មណ៍ ចំណេះដឹងសេរី និងបំណិនថ្លែងសុន្ទរកថា។

**3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**

បំណិនអក្សរសាស្ត្រជាមូលដ្ឋាន វេយ្យាករណ៍ ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ វិនាដសាស្ត្រ ទស្សនវិទូ ការនិយាយជាសាធារណៈ និងច្បាប់។

**4-ការរួមចំណែក និងឥទ្ធិពល**

តួនាទីនៃកម្លាំងជំរុញចិត្ត ក្នុងការសិក្សា ការទទួលស្គាល់ភាពខុសគ្នាខាងបុគ្គល។

**ឆ-អាឃ្វីណាស ១២២៥-១២៧៤ នៃគ.ស. (សាសនវិទូមជ្ឈិមសម័យអ៊ីតាលី)**

**1-ការតម្រង់ទិសខាងទស្សនវិជ្ជា**

សាសនវិទូគ្រិស្ត និងទស្សនវិជ្ជាតថភាពរបស់អារីស្តូត។

**2-ទស្សនៈស្ដីពីធម្មជាតិមនុស្ស**

មនុស្ស មានទាំងធម្មជាតិខាងចិត្ត និងរាងកាយ។

**3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**

ការអប់រំ គួរតែផ្អែកទៅលើធម្មជាតិមនុស្ស ដោយមានការសិក្សាសមរម្យសម្រាប់ចិត្ត និងរាងកាយ។

**4-ការរួមចំណែក និងឥទ្ធិពល**

-គ្រូជាភ្នាក់ងារសីលធម៌។ ការអប់រំទាក់ទងទៅនឹងសាសនវិទ្យាសកល។

-សំយោគខាងសាសនវិទ្យា និងទស្សនវិជ្ជា។

-មូលដ្ឋាននៃទស្សនវិជ្ជា បានប្រើប្រាស់ក្នុងសាលារៀនរ៉ូម៉ាំងកាតូលិក។

**ជ-អ៊ីរ៉ាស្មឹស ១៤៦៥-១៥៣៦ នៃគ.ស. (មនុស្សនិយមមុនសម័យហុល្លង់)**

**1-ការតម្រង់ទិសខាងទស្សនវិជ្ជា**

ការតម្រង់ទិសខាងសាសនាគ្រិស្ត អ្នកអប់រំ ជាអ្នករិះគន់ដោយឈ្លាសវៃ និង ទាក់ទង ដល់សង្គម។

**2-ទស្សនៈស្តីពីធម្មជាតិមនុស្ស**

មនុស្ស មានសមត្ថភាពបង្កើត សមិទ្ធផលដ៏ជ្រាលជ្រៅ តែក៏មានភាព ភ្លីភ្លើ ល្ងង់ខ្លៅខ្លាំងណាស់ដែរ។

**3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**

ការអប់រំ សម្រាប់វរជនអក្សរសាស្ត្រ ដែលសង្កត់ធ្ងន់ទៅលើការរិះគន់និយម និងការវិភាគ។

**4-ការរួមចំណែក និងឥទ្ធិពល**

តួនាទីនៃសាលាមធ្យមសិក្សា និង ឧត្តមសិក្សា ក្នុងការរិះគន់សង្គម និងអក្សរសាស្ត្រ ការសង្កត់ធ្ងន់ពីការគិតល្អិតល្អន់។

**ឈ-លូដ័រ ១៤៨៣-១៥៣៦ នៃ គ.ស.** (**ប្រូតែស្តង់អាល្លឺម៉ង់**)

**1-ការតម្រង់ទិសខាងទស្សនវិជ្ជា**

ការតម្រង់ទិសសាសនវិទ្យាប្រូតែស្តង់ ការសង្គ្រោះតាមជំនឿ និងមនសិការបុគ្គល។

**2-ទស្សនៈស្តីពីធម្មជាតិមនុស្ស**

មនុស្ស ត្រូវបានសង្គ្រោះដោយ ជំនឿ មនសិការបុគ្គលម្នាក់ៗ បង្កើតឡើង ដោយព្រះគម្ពីរ និងសាសនវិទ្យា ដែលបាន កែទម្រង់រួចហើយ។

**3-ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**

-សាលាបឋមសិក្សា ត្រូវបង្រៀន ការអាន ការសរសេរ នព្វន្តសាស្ត្រ សាសនា។

-សាលាមធ្យមសិក្សា ត្រូវត្រៀម រៀបចំមេដឹកនាំ តាមការផ្តល់ស្នាដៃ ប្រកបដោយគុណ សម្បត្តិ និងតម្លៃកំពូល ភាសា ក្រិក ឡាតាំង សាសនា និងការ បណ្តុះបណ្តាលវិជ្ជាជីវៈ។

**4-ការរួមចំណែក និងឥទ្ធិពល**

-ការសង្កត់ធ្ងន់ទៅលើសកលកម្ម អក្ខរកម្ម។

-សាលារៀនត្រូវសង្កត់ធ្ងន់ទៅលើ តម្លៃខាងសាសនា បំណិនវិជ្ជាជីវៈ ចំណេះ ដឹង។

-ទំនាក់ទំនងយ៉ាងជិតស្និទ្ធនៃ សាសនា សាលារៀន និងរដ្ឋ។

**ឯកសារយោង**

1-Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.

2-Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

3-Barzun, Jacques. *From Dawn to Decadence: 500 Years of Western Cultural Life, 1500 to the Present.* New York: HarperCollins, 2001.

4-Black, Robert. *Humanism and Education in Medieval and Renaissance Italy:Tradition and Innova tion in Latin Schools from the Twelfth to the Fifteenth Century.* New York:Cambridge Uni versity Press, 2001.

5-Gutek, Gerald. *Historical and Philosophical Foundations of Education: A Biographical Introduction.* Columbus, Ohio: Merrill/Prentice Hall, 2005.

6-Gutek, Gerald. *Historical and Philosophical Foundations of Education:Selected Readings.* Columbus, Ohio: Merrill/Prentice Hall, 2001.

7-Hanson, Victor D, and Heath, John. *Who Killed Homer? The Demise d of Classical Education and the Recovery of Greek Wisdom.* New York: Encounter Books, 2001.

8-Lascarides, V.Celia, and Hinitz, Blythe F. *History of Early Childhood Education.* New York:Falmer Press, 2000.

9-Palmer, Joy A, Cooper, David E., and Bresler, Liora, eds. *Fifty Major Thinkers on n Education:From Confucius to Dewey.* New York: Routledge, 2001.

10-Ruthven, Malise. *Islam in the World.* New York: Oxford University Press, 2000.